# **សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព**

KAISER PERMANENTE — NORTHERN CALIFORNIA REGION

សេចក្តីជូនដំណឹងនេះពណ៌នាអំពីរបៀបដែលព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកអាចត្រូវបានប្រើប្រាស់ និងលាតត្រដាង ព្រមទាំងរបៀបដែលអ្នកអាចចូលប្រើប្រាស់ព័ត៌មាននេះ។

សូមពិនិត្យមើលវាដោយយកចិត្តទុកដាក់។

នៅក្នុងសេចក្តីជូនដំណឹងនេះ យើងប្រើពាក្យ "យើង" "យើងខ្ញុំ" និង "របស់យើង" ដើម្បីពណ៌នាអំពី Kaiser Permanente — Northern California Region។ ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែម សូមមើលផ្នែក IV នៃសេចក្តីជូនដំណឹងនេះ

## **I. តើ "ព័ត៌មានសុខភាពដែលត្រូវបានការពារ" ជាអ្វី?**

ព័ត៌មានសុខភាពដែលត្រូវបានការពារ (Protected Health Information, PHI) របស់អ្នក គឺជាព័ត៌មានសុខភាពដែលអាចកំណត់អត្តសញ្ញាណបុគ្គល រួមមាន ព័ត៌មានប្រជាសាស្ត្រ ព័ត៌មានអំពីស្ថានភាពឬសុខភាពផ្លូវកាយឬផ្លូវចិត្តពីមុន បច្ចុប្បន្ន និងអនាគតរបស់អ្នក សេវាថែទាំសុខភាពដែលអ្នកទទួល និងព័ត៌មានអំពីការទូទាត់លើការថែទាំសុខភាពពីមុន បច្ចុប្បន្ន និងអនាគតរបស់អ្នក។ ព័ត៌មានប្រជាសាស្ត្រ សំដៅដល់ព័ត៌មាន ដូចជា ឈ្មោះ លេខសន្តិសុខសង្គម អាសយដ្ឋាន និងថ្ងៃខែឆ្នាំកំណើតរបស់អ្នក។ PHI ក៏រួមបញ្ចូលផងដែរនូវទិន្នន័យអំពី ពូជសាសន៍/ជាតិសាសន៍ ភាសា អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ និងសព្វនាម។

PHI អាចមានជាទម្រង់បែបបទផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក។ ឧទាហរណ៍អំពី PHI រួមមាន កំណត់ត្រាវេជ្ជសាស្ត្រ កំណត់ត្រាការទាមទារ ព័ត៌មានអំពីការចុះឈ្មោះ ឬការលុបឈ្មោះចេញរបស់អ្នក និងការប្រាស្រ័យទាក់ទងអំពីការថែទាំរបស់អ្នករវាងអ្នក និងអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ប្រសិនបើ PHI របស់អ្នកត្រូវបានលុបអត្តសញ្ញាណ ស្របទៅតាមស្តង់ដាច្បាប់ស្តីពីលទ្ធភាពចល័ត និងគណនេយ្យភាពនៃធានារ៉ាប់រងសុខភាព (Health Insurance Portability and Accountability Act, HIPAA) នោះវាលែងជា PHI ទៀតហើយ។

ប្រសិនបើអ្នកជាសមាជិកនៃគម្រោង Kaiser Foundation Health Plan និងជានិយោជិតរបស់ក្រុមហ៊ុន Kaiser Permanente ណាមួយ នោះ PHI មិនរួមបញ្ចូលព័ត៌មានសុខភាពនេះទៅក្នុងកំណត់ត្រាការងាររបស់អ្នកនោះទេ។

## **II. អំពីការទទួលខុសត្រូវរបស់យើងក្នុងការការពារ PHI របស់អ្នក**

តាមច្បាប់ យើងត្រូវ

1. ការពារឯកជនភាពនៃ PHI របស់អ្នក
2. ប្រាប់អ្នកអំពីសិទ្ធិរបស់អ្នក និងភារកិច្ចផ្លូវច្បាប់របស់យើងពាក់ព័ន្ធនឹង PHI របស់អ្នក
3. ជូនដំណឹងដល់អ្នក ប្រសិនបើមានការបែកធ្លាយលើ PHI ដែលគ្មានការធានាសុវត្ថិភាពរបស់អ្នក និង
4. ប្រាប់អ្នកអំពីទម្លាប់អនុវត្តនៃឯកជនភាពរបស់យើង និងអនុវត្តតាមសេចក្តីជូនដំណឹងជាធរមានបច្ចុប្បន្នរបស់យើង។

យើងយកចិត្តទុកដាក់ខ្ពស់ចំពោះការទទួលខុសត្រូវទាំងនេះ និងបានអនុវត្តការការពារសុវត្ថិភាព រដ្ឋបាល (ដូចជា ការបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីសុវត្ថិភាព ក៏ដូចជាគោលនយោបាយ និងនីតិវិធីនានា) ការការពារសុវត្ថិភាពផ្នែកបច្ចេកទេស (ដូចជា ការអ៊ិនគ្រីប និងពាក្យសម្ងាត់) និងការការពារសុវត្ថិភាពទីតាំងផ្ទាល់ (ដូចជា កន្លែងចាក់សោ និងការតម្រូវឱ្យមានបណ្ណសម្គាល់) ដើម្បីការពារ PHI របស់អ្នក ហើយដូចពីមុនមកដែរ យើងនឹងបន្តចាត់វិធានការសមស្របដើម្បីការពារសុវត្ថិភាពឯកជនភាពនៃ PHI របស់អ្នក។

យើងអាចបង្ហាញព័ត៌មាន PHI របស់អ្នកទៅកាន់អ្នកដទៃ ដូចដែលបានរៀបរាប់នៅក្នុងទំព័របន្តបន្ទាប់ ដោយអនុលោមតាមការអនុញ្ញាតដែលផ្តល់ដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធភាពចល័ត និងគណនេយ្យភាពនៃធានារ៉ាប់រងសុខភាព (HIPAA)។ រាល់ការបង្ហាញព័ត៌មាន PHI របស់អ្នកបន្ថែមទៀតដោយអ្នកទទួល នឹងលែងត្រូវបានការពារដោយ HIPAA ទៀតហើយ។

## III. សិទ្ធិរបស់អ្នកទាក់ទងនឹង PHI របស់អ្នក

ផ្នែកនេះប្រាប់អ្នកអំពីសិទ្ធិរបស់អ្នកពាក់ព័ន្ធនឹង PHI របស់អ្នក និងរបៀបដែលអ្នកអាចអនុវត្តសិទ្ធិទាំងនេះ។

### សិទ្ធិរបស់អ្នកក្នុងការចូលប្រើប្រាស់ និងកែប្រែ PHI របស់អ្នក

ក្នុងករណីលើកលែងមួយចំនួន អ្នកមានសិទ្ធិមើល ឬទទួលបានច្បាប់ចម្លង PHI របស់អ្នកដែលយើងរក្សាទុកនៅក្នុងកំណត់ត្រាពាក់ព័ន្ធនឹងការថែទាំ ឬការសម្រេចចិត្តរបស់អ្នកអំពីការថែទាំ ឬការបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក។ ក្នុងករណីលើកលែងមួយចំនួន ការស្នើសុំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ យើងអាចនឹងគិតថ្លៃទៅតាមការចំណាយសមស្របសម្រាប់ច្បាប់ចម្លង ខ្លឹមសារសង្ខេប ឬការពន្យល់អំពី PHI របស់អ្នក។

ប្រសិនបើយើងមិនមានកំណត់ត្រាដែលអ្នកបានស្នើសុំ ប៉ុន្តែយើងស្គាល់អ្នកដែលមានកំណត់ត្រានោះ យើងនឹងប្រាប់អ្នកថាតើអ្នកត្រូវទាក់ទងទៅនរណាដើម្បីស្នើសុំកំណត់ត្រានោះ។ ក្នុងស្ថានភាពមានការដាក់កំហិត យើងអាចនឹងបដិសេធចំពោះសំណើសុំមើល ឬទទួលបានច្បាប់ចម្លងកំណត់ត្រារបស់អ្នកមួយចំនួនឬទាំងស្រុង ប៉ុន្តែបើយើងបដិសេធ យើងនឹងប្រាប់អ្នកជាលាយលក្ខណ៍អក្សរអំពីមូលហេតុ និងពន្យល់អំពីសិទ្ធិរបស់អ្នក (បើមាន) ដើម្បីឱ្យពិនិត្យមើលការបដិសេធរបស់យើង។

ប្រសិនបើអ្នកជឿជាក់ថាមានកំហុសអ្វីមួយនៅក្នុង PHI របស់អ្នក ឬជឿជាក់ថាបាត់ព័ត៌មានសំខាន់ អ្នកអាចស្នើសុំឱ្យយើងកែតម្រូវ ឬបញ្ចូលព័ត៌មានទៅក្នុងកំណត់ត្រានោះបាន។ សំណើសុំត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងប្រាប់យើងអំពីការកែតម្រូវ ឬការបញ្ចូលអ្វីខ្លះដែលអ្នកកំពុងស្នើសុំ ព្រមទាំងមូលហេតុដែលត្រូវធ្វើការកែតម្រូវ ឬការបញ្ចូលនោះ។ យើងនឹងឆ្លើយតបជាលាយលក្ខណ៍អក្សរ បន្ទាប់ពីពិនិត្យមើលសំណើរបស់អ្នក។ ប្រសិនបើយើងឯកភាពលើសំណើរបស់អ្នក យើងនឹងធ្វើការកែតម្រូវ ឬបញ្ចូលព័ត៌មាននោះទៅក្នុង PHI របស់អ្នក។ ប្រសិនបើយើងបដិសេធសំណើរបស់អ្នក យើងនឹងប្រាប់អ្នកអំពីមូលហេតុ និងពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការដាក់ពាក្យស្នើសុំការបញ្ជាក់អំពីការមិនឯកភាពជាលាយលក្ខណ៍អក្សរ។ សេចក្តីបញ្ជាក់របស់អ្នកត្រូវតែកំណត់ត្រឹម 250 ពាក្យ សម្រាប់ចំណុចនីមួយៗនៅក្នុងកំណត់ត្រារបស់អ្នកដែលអ្នកជឿជាក់ថាមិនត្រឹមត្រូវ ឬមិនពេញលេញ។ អ្នកត្រូវប្រាប់យើងឱ្យបានច្បាស់ជាលាយលក្ខណ៍អក្សរ ប្រសិនបើអ្នកចង់ឱ្យយើងរួមបញ្ចូលសេចក្តីបញ្ជាក់របស់អ្នកនៅក្នុងការលាតត្រដាងនាពេលខាងមុខដែលយើងធ្វើឡើងជាផ្នែកមួយនៃកំណត់ត្រារបស់អ្នក។ យើងអាចរួមបញ្ចូលសេចក្តីសង្ខេបជំនួសឱ្យសេចក្តីបញ្ជាក់របស់អ្នក។

សូមដាក់បញ្ជូនសំណើជាលាយលក្ខណ៍អក្សរទាំងអស់ទៅមន្ទីរព្យាបាល ឬការិយាល័យវេជ្ជសាស្ត្ររបស់ Kaiser Permanente ដែលអ្នកបានទទួលការថែទាំរបស់អ្នក។ ប្រសិនបើអ្នកត្រូវការអាសយដ្ឋាននោះ សូមហៅទូរសព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាបម្រើសមាជិកតាមលេខ 1-800-464-4000 (TTY 711)។ ប៉ុន្តែ ប្រសិនបើអ្នកមិនដឹងថាកំណត់ត្រាដែលអ្នកចង់បាននៅកន្លែងណាទេ សូមសរសេរសំបុត្រមកយើងខ្ញុំតាមរយៈ Director of Privacy & Security Compliance, Kaiser Permanente Ethics & Compliance Office, 1 Kaiser Plaza, Oakland, CA 94612, 19th Floor។

## សិទ្ធិរបស់អ្នកក្នុងការជ្រើសរើសវិធីដែលយើងផ្ញើ PHI ទៅកាន់អ្នក ឬនរណាម្នាក់ផ្សេងទៀត

អ្នកអាចសុំឱ្យយើងខ្ញុំផ្ញើ PHI របស់អ្នកទៅឱ្យអ្នកនៅអាសយដ្ឋានផ្សេងបាន (ឧទាហរណ៍ អាសយដ្ឋានកន្លែងការងាររបស់អ្នក) ឬតាមរយៈមធ្យោបាយផ្សេង (ឧទាហរណ៍ ទូរសារជំនួសឱ្យអាសយដ្ឋានប្រៃសណីយ៍ធម្មតា)។

ប្រសិនបើ PHI របស់អ្នកត្រូវបានរក្សាទុកតាមប្រព័ន្ធអេឡិចត្រូនិក អ្នកអាចស្នើសុំច្បាប់ចម្លងកំណត់ត្រាជាទម្រង់អេឡិចត្រូនិកដែលផ្តល់ជូនដោយ Kaiser Permanente។ អ្នកក៏អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ Kaiser Permanente ឱ្យផ្ញើច្បាប់ចម្លង PHI របស់អ្នកទៅកាន់ភាគីទីបីដែលបានចាត់តាំងផងដែរ។ យើងអាចនឹងគិតថ្លៃតាមការចំណាយសមស្រប។

## សិទ្ធិរបស់អ្នកក្នុងការទទួលបានការប្រាស្រ័យទាក់ទងជាសម្ងាត់

អ្នកមានសិទ្ធិស្នើឱ្យយើងទាក់ទងជាមួយអ្នកពាក់ព័ន្ធនឹងបញ្ហាសុខភាពតាមអាសយដ្ឋានប្រៃសណីយ៍ អាសយដ្ឋានអ៊ីមែល ឬលេខទូរសព្ទផ្សេង។

អ្នកត្រូវផ្តល់អាសយដ្ឋានផ្សេងនោះមកយើង ដើម្បីឱ្យយើងអាចធ្វើការទំនាក់ទំនងពាក់ព័ន្ធនឹងសេវាសំខាន់ៗ (សេវាថែទាំសុខភាពទាក់ទងនឹងសុខភាពផ្លូវចិត្ត ឬអាកប្បកិរិយា សុខភាពផ្លូវភេទ និងការបន្តពូជ ជំងឺកាមរោគ វិបត្តិប្រើប្រាស់សារធាតុញៀន ការថែទាំដោយបញ្ជាក់ពីយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ) ទៅអ្នកដោយផ្ទាល់។ ប្រសិនបើអ្នកមិនផ្តល់អាសយដ្ឋានផ្សេងទេ យើងនឹងផ្ញើការប្រាស្រ័យទាក់ទងទាំងអស់ពាក់ព័ន្ធនឹងការទទួលសេវាសំខាន់ៗរបស់អ្នកជំនួសឱ្យអ្នកតាមអាសយដ្ឋាន ឬលេខទូរសព្ទនៅលើឯកសារ។

ការប្រាស្រ័យទាក់ទងដែលស្ថិតក្នុងកថាខណ្ឌនេះត្រូវរួមបញ្ចូលការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ ផ្ទាល់មាត់ ឬអេឡិចត្រូនិក៖

(i) វិក្កយបត្រ និងការព្យាយាមប្រមូលប្រាក់ទូទាត់។

(ii) សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចុងក្រោយលើការបដិសេធអត្ថប្រយោជន៍។

(iii) សេចក្តីជូនដំណឹងពីការពន្យល់អំពីអត្ថប្រយោជន៍។

(iv) សំណើរបស់ក្រុមហ៊ុនធានារ៉ាប់រងសុខភាពចំពោះព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការទាមទារសំណង។

(v) សេចក្តីជូនអំណឹងអំពីការទាមទារដែលត្រូវបានជំទាស់។

(vi) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្តល់សេវា ការពណ៌នាអំពីសេវាដែលបានផ្តល់ និងព័ត៌មានផ្សេងទៀតទាក់ទងនឹងការជួបពិគ្រោះ។

(vii) ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ ផ្ទាល់មាត់ ឬអេឡិចត្រូនិករបស់ក្រុមហ៊ុនធានារ៉ាប់រងសុខភាពដែលមានព័ត៌មានសុខភាពដែលត្រូវបានការពារ។

ដើម្បីផ្តល់អាសយដ្ឋានសម្ងាត់សម្រាប់ទទួលការប្រាស្រ័យទាក់ទងជាសម្ងាត់ អ្នកអាចបំពេញទម្រង់បែបបទសំណើស្តីពីការប្រាស្រ័យទាក់ទងជាសម្ងាត់ដែលបិតនៅខាងក្រោមទំព័រដើម KP.org (ជាភាសាអង់គ្លេស) ឬទាក់ទងមកមជ្ឈមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាបម្រើសមាជិកតាមលេខ 1-800-464-4000 (TTY 711) ដើម្បីទទួលបានជំនួយ។

### សិទ្ធិរបស់អ្នកក្នុងការទទួលបានកំណត់ត្រាស្តីពីការលាតត្រដាង PHI

អ្នកអាចស្នើសុំតារាងលាតត្រដាង PHI របស់អ្នកពីយើងបាន។ សូមសរសេរសំបុត្រមកយើងខ្ញុំតាមរយៈ Director of Privacy & Security Compliance, Kaiser Permanente Ethics & Compliance Office, 1 Kaiser Plaza, Oakland, CA 94612, 19th Floor។ អ្នកមានសិទ្ធិទទួលបានកំណត់ត្រាស្តីពីការលាតត្រដាងក្នុងរយៈពេល 12 ខែដោយឥតគិតថ្លៃ។ ប្រសិនបើអ្នកស្នើសុំកំណត់ត្រាបន្ថែមទៀតណាមួយក្នុងរយៈពេលតិចជាង 12 ខែបន្ទាប់ យើងអាចនឹងគិតថ្លៃសេវា។

កំណត់ត្រាមិនរួមបញ្ចូលការលាតត្រដាងជាក់លាក់ទេ ឧទាហរណ៍ ការលាតត្រដាង៖

- ដើម្បីធ្វើការព្យាបាល ការបង់ប្រាក់ និងកិច្ចដំណើរការថែទាំសុខភាព
- ដែល Kaiser Permanente បានអនុញ្ញាតដោយមានការចុះហត្ថលេខា
- អំពី PHI របស់អ្នកទៅអ្នក
- ពីបញ្ជីរាយឈ្មោះទីតាំងរបស់ Kaiser Permanente
- សម្រាប់ការជូនដំណឹងក្នុងគោលបំណងផ្តល់ជំនួយនៅពេលមានគ្រោះមហន្តរាយ
- ដល់បុគ្គលដែលពាក់ព័ន្ធនឹងការថែទាំរបស់អ្នក និងបុគ្គលដែលធ្វើសកម្មភាពជំនួសអ្នក ឬ
- ដែលមិនបានរ៉ាប់រងដោយសិទ្ធិក្នុងការទទួលបានកំណត់ត្រា។

អ្នកមានសិទ្ធិទទួលបានបញ្ជីនៃការបង្ហាញព័ត៌មានដោយអន្តរការីសម្រាប់ឯកសារដែលត្រូវបានបង្ហាញដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរនៅក្នុងកម្មវិធី SUD Program។ បញ្ជីនៃការបង្ហាញព័ត៌មានគឺត្រូវបានកំណត់ត្រឹមតែការបង្ហាញព័ត៌មានដែលបានធ្វើឡើងក្នុងរយៈពេល 3 ឆ្នាំចុងក្រោយ គិតចាប់ពីថ្ងៃដែលអ្នកបានដាក់សំណើ។

### សិទ្ធិរបស់អ្នកក្នុងការស្នើសុំដាក់ដែនកំណត់លើការប្រើប្រាស់ និងការលាតត្រដាង PHI របស់អ្នក

អ្នកអាចនឹងស្នើសុំឱ្យយើងដាក់ដែនកំណត់លើការប្រើប្រាស់ និងការលាតត្រដាង PHI របស់អ្នកក្នុងគោលបំណងព្យាបាល ការបង់ប្រាក់ និងកិច្ចដំណើរការថែទាំសុខភាព។ យើងនឹងពិនិត្យ និងពិចារណាសំណើរបស់អ្នក។ អ្នកអាចសរសេរសំបុត្រទៅកាន់មន្ទីរពេទ្យ ឬការិយាល័យវេជ្ជសាស្ត្ររបស់ Kaiser Permanente ដែលអ្នកបានទទួលការថែទាំ សម្រាប់ការពិចារណាលើសំណើរបស់អ្នកបាន។ ប្រសិនបើអ្នកត្រូវការអាសយដ្ឋាននោះ សូមហៅទូរសព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាបម្រើសមាជិកតាមលេខ 1-800-464-4000 (TTY 711)។ ប៉ុន្តែ ប្រសិនបើអ្នកមិនដឹងថាកំណត់ត្រាដែលអ្នកចង់បាននៅកន្លែងណាទេ សូមសរសេរសំបុត្រមកយើងខ្ញុំតាមរយៈ Director of Privacy & Security Compliance, Kaiser Permanente Ethics & Compliance Office, 1 Kaiser Plaza, Oakland, CA 94612, 19th Floor។

យើងមិនចាំបាច់ត្រូវយល់ព្រមចំពោះសំណើរបស់អ្នកទេ លើកលែងតែក្នុងករណីដែលអ្នកសុំការរឹតបន្តឹងលើការលាតត្រដាងដល់គម្រោងសុខភាព ឬក្រុមហ៊ុនធានារ៉ាប់រង ក្នុងគោលបំណងទូទាត់ ឬកិច្ចដំណើរការថែទាំសុខភាព និងសម្ភារៈ ឬសេវាកម្មដែលត្រូវបានទូទាត់ដោយប្រាក់ពីហោប៉ៅផ្ទាល់ខ្លួនគ្រប់ចំនួន។ ប៉ុន្តែ យើងនៅតែលាតត្រដាងព័ត៌មាននេះទៅកាន់គម្រោងសុខភាព ឬក្រុមហ៊ុនធានារ៉ាប់រង ក្នុងគោលបំណងព្យាបាលអ្នក។ ប្រសិនបើសេវាកម្មនានាមិនត្រូវបានបង់ប្រាក់គ្រប់ចំនួន និងចេញពីហោប៉ៅដោយអ្នក ឬដោយនរណាម្នាក់ក្នុងនាមអ្នកនោះទេ យើងមិនចាំបាច់យល់ព្រមតាមសំណើរបស់អ្នកក្នុងការរឹតបន្តឹងការប្រើប្រាស់ ឬការបង្ហាញព័ត៌មាន PHI សម្រាប់គោលបំណងប្រតិបត្តិការថែទាំសុខភាព ការបង់ប្រាក់ ឬការព្យាបាលឡើយ។ សម្រាប់សំណើសុំឱ្យរឹតបន្តឹង PHI របស់អ្នកក្នុងគោលបំណងទូទាត់ និងកិច្ចដំណើរការថែទាំសុខភាព សូមស្នើសុំការរឹតបន្តឹងនៅមុនពេលទទួលបានសេវានៅតាមមន្ទីរពេទ្យ ឬការិយាល័យវេជ្ជសាស្ត្ររបស់ Kaiser Permanente ដែលអ្នកទទួលការថែទាំ។

**សិទ្ធិរបស់អ្នកក្នុងការទទួលបានច្បាប់ចម្លងជាក្រដាសនៃសេចក្តីជូនដំណឹងនេះ**

អ្នកក៏មានសិទ្ធិទទួលបានច្បាប់ចម្លងជាក្រដាសនៃសេចក្តីជូនដំណឹងនេះតាមការស្នើសុំផងដែរ។

## IV. ក្រុមហ៊ុន KAISER PERMANENTE ត្រូវគោរពតាមសេចក្តីជូនដំណឹងនេះ

សេចក្តីជូនដំណឹងនេះអនុវត្តចំពោះ Kaiser Permanente, Northern California Region ដែលរួមមាន

- The Permanente Medical Group (TPMG)
- Kaiser Foundation Health Plan, Inc., ដោយរួមបញ្ចូលគម្រោងសុខភាព និងកិច្ចដំណើរការរបស់អ្នកផ្តល់សេវា និង
- មន្ទីរពេទ្យរបស់ Kaiser Foundation Hospitals (KFH)។

ទីតាំងផ្តល់សេវាថែទាំសុខភាពរបស់យើងរួមមាន ការិយាល័យវេជ្ជសាស្ត្រ Kaiser Permanente មន្ទីរពេទ្យ និងមជ្ឈមណ្ឌលវះកាត់ដោយមិនស្នាក់នៅមន្ទីរពេទ្យ ព្រមទាំងមូលដ្ឋានអាជីវកម្ម Kaiser Permanente ផ្សេងទៀតនៅក្នុងតំបន់ មជ្ឈមណ្ឌលផ្តល់ប្រឹក្សានិងណាត់ជួបតាមទូរសព្ទសម្រាប់សមាជិក និងគេហទំព័រ ព្រមទាំងកម្មវិធីទូរសព្ទរបស់យើង។

ដើម្បីផ្តល់សេវាថែទាំសុខភាពដែលអ្នកចង់បាន ផ្តល់ការព្យាបាលដល់អ្នក ទូទាត់សម្រាប់ការថែទាំរបស់អ្នក និងធ្វើប្រតិបត្តិការរបស់យើង ដូចជា ការធានាគុណភាព ការទទួលស្គាល់ ការផ្តល់អាជ្ញាបណ្ណនិងអនុលោមភាព ក្រុមហ៊ុន Kaiser Permanente ទាំងនេះនឹងចែករំលែក PHI របស់អ្នកដល់គ្នាទៅវិញទៅមក។

បុគ្គលិករបស់យើងអាចនឹងចូលប្រើ PHI របស់អ្នកក្នុងនាមជានិយោជិត គ្រូពេទ្យ ក្រុមបុគ្គលិកជំនាញវិជ្ជាជីវៈរបស់មន្ទីរពេទ្យ KFH និងអ្នកផ្សេងទៀតដែលទទួលបានការអនុញ្ញាតឱ្យបញ្ចូលព័ត៌មាននៅក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ KFH អ្នកស្ម័គ្រចិត្ត ឬបុគ្គលដែលធ្វើការងារជាមួយយើងនៅក្នុងសមាសភាពដទៃផ្សេងទៀត។

## V. របៀបដែលយើងអាចប្រើប្រាស់ និងបញ្ចេញ PHI របស់អ្នក

ការសម្ងាត់របស់អ្នកមានសារៈសំខាន់សម្រាប់យើង។ គ្រូពេទ្យនិងបុគ្គលិករបស់យើង ចាំបាច់ត្រូវរក្សាការសម្ងាត់នៃ PHI របស់សមាជិក/អ្នកជំងឺរបស់យើង ហើយយើងមានគោលការណ៍ និងនីតិវិធី ព្រមទាំងកិច្ចការពារសុវត្ថិភាពផ្សេងទៀត ដើម្បីជួយការពារ PHI របស់អ្នកមិនឱ្យមានការប្រើប្រាស់ និងការលាតត្រដាងមិនសមស្រប។ ជួនកាល ច្បាប់អនុញ្ញាតឱ្យយើងប្រើប្រាស់ និងលាតត្រដាង PHI មួយចំនួនដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកឡើយ។ យើងរៀបរាប់ដោយសង្ខេបអំពីការប្រើប្រាស់ និងការលាតត្រដាងទាំងនេះដូចខាងក្រោម និងផ្តល់ឧទាហរណ៍មួយចំនួនដល់អ្នក។

ឧទាហរណ៍ កម្រិតដែល PHI ត្រូវបានប្រើប្រាស់ និងលាតត្រដាងដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនឹងប្រែប្រួលដោយអាស្រ័យលើគោលបំណងប្រើប្រាស់ ឬលាតត្រដាងដែលចង់បាន។ ជួនកាលយើងអាចគ្រាន់តែចាំបាច់ត្រូវប្រើប្រាស់ ឬលាតត្រដាង PHI ក្នុងកម្រិតតិចតួចប៉ុណ្ណោះ ដូចជា ដើម្បីផ្ញើជូនការរំលឹកអំពីការណាត់ជួបដល់អ្នក ឬដើម្បីបញ្ជាក់ថាអ្នកជាសមាជិកគម្រោងសុខភាព។ ជួនកាលទៀត យើងអាចនឹងចាំបាច់ត្រូវប្រើប្រាស់ និងលាតត្រដាង PHI ច្រើន ដូចជា នៅពេលយើងកំពុងផ្តល់សេវាថែទាំវេជ្ជសាស្ត្រជាដើម។

- **ការព្យាបាល៖** នេះជាការប្រើប្រាស់ និងការលាតត្រដាង PHI របស់អ្នកសំខាន់បំផុត។ ឧទាហរណ៍ គ្រូពេទ្យ គិលានុបដ្ឋាក និងបុគ្គលិកថែទាំសុខភាពផ្សេងទៀតរបស់យើង រួមមានសិក្ខាកាមជាដើម ដែលចូលរួមទៅក្នុងការថែទាំសុខភាពអ្នក គឺពួកគេប្រើប្រាស់និងលាតត្រដាង PHI របស់អ្នកដើម្បីធ្វើរោគវិនិច្ឆ័យស្ថានភាពសុខភាពរបស់អ្នក និងវាយតម្លៃលើតម្រូវការថែទាំសុខភាពរបស់អ្នក។ បុគ្គលិករបស់យើងនឹងប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នក ដើម្បីផ្តល់និងសម្របសម្រួលដល់ការថែទាំនិងសេវាដែលអ្នកត្រូវការ៖ ឧទាហរណ៍ វេជ្ជបញ្ជា ការថតកាំរស្មីអ៊ិច និងការងារមន្ទីរពិសោធ។ ប្រសិនបើអ្នកត្រូវការការថែទាំពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមិនមែនជាផ្នែកមួយនៃ Kaiser Permanente ដូចជា ធនធានតាមសហគមន៍ជាដើម ដើម្បីជួយដល់តម្រូវការថែទាំសុខភាពរបស់អ្នកតាមផ្ទះ យើងអាចលាតត្រដាង PHI របស់អ្នកដល់ពួកគេបាន។

- **ការទូទាត់៖** PHI របស់អ្នកអាចនឹងត្រូវការចាំបាច់ ដើម្បីកំណត់ការទទួលខុសត្រូវរបស់យើងក្នុងការទូទាត់ ឬដើម្បីអនុញ្ញាតឱ្យយើងចេញវិក្កយបត្រទូទាត់ និងប្រមូលប្រាក់ទូទាត់សម្រាប់ការព្យាបាល និងសេវាពាក់ព័ន្ធនឹងសុខភាពដែលអ្នកទទួល។ ឧទាហរណ៍ យើងអាចនឹងមានកាតព្វកិច្ចបង់ប្រាក់សម្រាប់ការថែទាំសុខភាពដែលអ្នកទទួលបានពីអ្នកផ្តល់សេវាខាងក្រៅ។ នៅពេលអ្នក ឬអ្នកផ្តល់សេវាផ្ញើវិក្កយបត្រទូទាត់សេវាថែទាំសុខភាព យើងប្រើប្រាស់និងលាតត្រដាង PHI របស់អ្នក ដើម្បីកំណត់ថ្លៃចំណាយចំនួនប៉ុន្មាន (បើមាន) នៅលើវិក្កយបត្រដែលយើងត្រូវទទួលខុសត្រូវធ្វើការទូទាត់។

- **ដំណើរការថែទាំសុខភាព៖** យើងអាចប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នកសម្រាប់កិច្ចដំណើរការថែទាំសុខភាពជាក់លាក់ ឧទាហរណ៍ ការវាយតម្លៃលើគុណភាពនិងការកែលម្អ ការបណ្តុះបណ្តាលនិងការវាយតម្លៃលើអ្នកជំនាញថែទាំសុខភាព ការផ្តល់អាជ្ញាបណ្ណ ការទទួលស្គាល់ និងការកំណត់បុព្វលាភរ៉ាប់រង និងថ្លៃចំណាយផ្សេងៗលើការផ្តល់សេវាថែទាំសុខភាព។

- **ដៃគូអាជីវកម្ម៖** យើងអាចនឹងចុះកិច្ចសន្យាជាមួយសម្ព័ន្ធក្រុមហ៊ុនអាជីវកម្ម ដើម្បីបំពេញនូវមុខងារ ឬសកម្មភាពជាក់លាក់ជំនួសឱ្យយើង ដូចជា ការទូទាត់ និងដំណើរការថែទាំសុខភាព។ សម្ព័ន្ធក្រុមហ៊ុនអាជីវកម្មទាំងនេះត្រូវយល់ព្រមការពារសុវត្ថិភាព PHI របស់អ្នក។

- **ការរំលឹកអំពីការណាត់ជួប៖** យើងអាចនឹងប្រើប្រាស់ PHI របស់អ្នក ដើម្បីទាក់ទងទៅអ្នកអំពីការណាត់ជួបសម្រាប់ព្យាបាល ឬការថែទាំសុខភាពផ្សេងទៀតដែលអ្នកត្រូវការ។

- **ការផ្ទៀងផ្ទាត់អត្តសញ្ញាណ៖** យើងអាចនឹងថតរូបអ្នកដើម្បីបញ្ជាក់អត្តសញ្ញាណ ដោយរក្សាទុករូបថតនោះនៅក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក។ ការធ្វើបែបនេះគឺដើម្បីការពារ និងរក្សាសុវត្ថិភាពរបស់អ្នក ប៉ុន្តែអ្នកអាចជ្រើសរើសមិនចូលរួមបាន។

- **ការផ្លាស់ប្តូរព័ត៌មានសុខភាព៖**
  យើងអាចនឹងចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នផ្សេងទៀតតាមរយៈបណ្តាញការផ្លាស់ប្តូរព័ត៌មានសុខភាព (HIE)។ ស្ថាប័នទាំងនេះអាចរួមមានមន្ទីរពេទ្យ មន្ទីរពិសោធ អ្នកផ្តល់សេវាថែទាំសុខភាព ក្រសួងសុខាភិបាលសាធារណៈ គម្រោងសុខភាព និងអ្នកចូលរួមផ្សេងទៀត។ Kaiser Permanente ដំណើរការបណ្តាញការផ្លាស់ប្តូរព័ត៌មានសុខភាព (Health Information Exchange, HIE) នៅតាមតំបន់របស់ Kaiser Permanente និងអ្នកចូលរួមក្នុងបណ្តាញ HIE មួយចំនួនដែលមានអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀតនៅក្រៅ Kaiser Permanente ដែលមានប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្រតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ការចែករំលែកព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក គឺជាមធ្យោបាយឆាប់រហ័សដើម្បីផ្តល់ព័ត៌មានសុខភាពរបស់អ្នកទៅដល់អ្នកផ្តល់សេវាថែទាំសុខភាពដែលព្យាបាលអ្នក។ ឧទាហរណ៍ បើអ្នកចូលបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យដែលអ្នកចូលរួមនៅក្នុងបណ្តាញ HIE ដូចគ្នានឹង Kaiser Permanente ដែរ គ្រូពេទ្យនៅបន្ទប់សង្គ្រោះបន្ទាន់ នឹងអាចចូលមើលព័ត៌មានសុខភាពរបស់អ្នកនៅ Kaiser Permanente ដើម្បីធ្វើការសម្រេចចិត្តលើការព្យាបាលសម្រាប់អ្នក។ អ្នកចូលរួមក្នុង HIE ដូចជា Kaiser Permanente ត្រូវបំពេញតាមវិធានដែលការពារឯកជនភាព និងសុវត្ថិភាពនៃព័ត៌មានសុខភាព និងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។

  - ការចូលរួមក្នុង HIE គឺជាជម្រើសរបស់អ្នក។ អ្នកអាចជ្រើសរើសមិនចែករំលែកព័ត៌មានរបស់អ្នកតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ HIE (“ជ្រើសរើសមិនចូលរួម”) នៅពេលណាក៏បាន ដោយបំពេញទម្រង់បែបបទ ជ្រើសរើសមិនចូលរួមផ្លាស់ប្តូរព័ត៌មានសុខភាព ដែលមាននៅទីនេះ។ ប្រសិនបើអ្នកជ្រើសរើសមិនចូលរួមជាមួយ HIE វានឹងមិនប៉ះពាល់ដល់ការទទួលបានការថែទាំរបស់អ្នកនៅ Kaiser Permanente តាមមធ្យោបាយណាមួយឡើយ។

  - ប្រសិនបើកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកមានព័ត៌មានជាក់លាក់ (ដូចជា ព័ត៌មានពីកម្មវិធីវិបត្តិប្រើប្រាស់សារធាតុញៀន) ដែលតាមច្បាប់រដ្ឋ ឬសហព័ន្ធតម្រូវឱ្យមានការយល់ព្រមពីអ្នកមុនពេលចែករំលែក នោះ Kaiser Permanente នឹងមិនបញ្ជូនព័ត៌មាននោះទៅឱ្យអ្នកផ្តល់សេវាព្យាបាលផ្សេងទៀតរបស់អ្នកតាមរយៈ HIE ទេ ប្រសិនបើអ្នកមិនផ្តល់ការយល់ព្រម។ ដើម្បីពិនិត្យមើលថាតើត្រូវតម្រូវឱ្យមានការយល់ព្រមពីអ្នកមុនពេល Kaiser Permanente អាចបង្ហាញកំណត់ត្រារបស់អ្នកតាមរយៈ HIE ឬអត់ ឬដើម្បីផ្តល់ការយល់ព្រម សូមចុចទីនេះ
    https://healthy.kaiserpermanente.org/health/mycare/consumer/my-health-manager/my-medical-record/authorize-sharing/

  - អនុលោមតាមច្បាប់របស់រដ្ឋ California ព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធនឹង ការរំលូតកូន និងសេវាកម្មពាក់ព័ន្ធនឹងការរំលូតកូន នឹងមិនត្រូវបានចែករំលែកតាមរយៈ HIE ជាមួយអង្គភាពនានានៅក្រៅរដ្ឋ California ឡើយ លុះត្រាតែអ្នកបានផ្តល់ការអនុញ្ញាតដែលមានសុពលភាព ឬការចែករំលែកនោះត្រូវបានអនុញ្ញាតដោយច្បាប់ដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នក។

- **ប្រភេទ PHI មួយចំនួន៖** មានលក្ខខណ្ឌតម្រូវតឹងរ៉ឹងជាងនេះសម្រាប់ការប្រើប្រាស់និងលាតត្រដាងប្រភេទ PHI មួយចំនួន — ឧទាហរណ៍ ព័ត៌មានអ្នកជំងឺផ្លូវចិត្ត និងការប្រើប្រាស់ញៀននិងគ្រឿងស្រវឹង ការធ្វើតេស្តវីរុស HIV និងព័ត៌មានអំពីការធ្វើតេស្តហ្សែន។ ប៉ុន្តែនៅតែមានស្ថានភាពមួយចំនួនដែលប្រភេទព័ត៌មានទាំងនេះ អាចនឹងមិនត្រូវបានប្រើប្រាស់ ឬលាតត្រដាងដោយគ្មានការអនុញ្ញាតពីអ្នក។ ប្រសិនបើអ្នកក្លាយជាអ្នកជំងឺនៅក្នុងកម្មវិធីវិបត្តិនៃការប្រើប្រាស់សារធាតុញៀន (SUD) របស់យើង យើងនឹងផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដាច់ដោយឡែកមួយដល់អ្នក ដូចដែលបានតម្រូវដោយច្បាប់អំពីសិទ្ធិឯកជនភាពរបស់អ្នកសម្រាប់ព័ត៌មាន PHI នៃកម្មវិធី SUD របស់អ្នក។
- សម្រាប់ការប្រើប្រាស់ និងការបង្ហាញកំណត់ត្រានៃវិបត្តិនៃការប្រើប្រាស់សារធាតុញៀន (SUD) របស់អ្នកដែលទទួលបានពីកម្មវិធី SUD អ្នកអាចផ្តល់ការយល់ព្រមតែម្តងសម្រាប់រាល់ការប្រើប្រាស់ ឬការបង្ហាញព័ត៌មាននាពេលអនាគត សម្រាប់គោលបំណងនៃការព្យាបាល ការបង់ប្រាក់ និងប្រតិបត្តិការថែទាំសុខភាព ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីជូនដំណឹងនេះ។ នៅពេលដែលការយល់ព្រមតែម្តងត្រូវបានផ្តល់ឱ្យ យើងអាចប្រើប្រាស់និងបង្ហាញកំណត់ត្រាទាំងនោះសម្រាប់ការព្យាបាល ការបង់ប្រាក់ និងដំណើរការថែទាំសុខភាព ដូចដែលត្រូវបានអនុញ្ញាតដោយបទប្បញ្ញត្តិ HIPAA លុះត្រាតែអ្នកដកហូតការយល់ព្រមរបស់អ្នកជាលាយលក្ខណ៍អក្សរ។
- **ការធានា៖** យើងអាចនឹងប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នក ក្នុងកម្រិតដែលច្បាប់ជាធរមានបានអនុញ្ញាត សម្រាប់គោលបំណងធានា ដោយរួមបញ្ចូល សេចក្តីសម្រេចចុងក្រោយលើសិទ្ធិទទួលបានអត្ថប្រយោជន៍ និងថ្លៃចំណាយលើការធានារ៉ាប់រង និងដើម្បីធ្វើសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងការចេញគោលការណ៍ស្តីពីអត្ថប្រយោជន៍។ ប៉ុន្តែយើងដកចេញពីការពិនិត្យឡើងវិញ ឬការបង្ហាញសម្រាប់គោលបំណងធានារ៉ាប់រងនូវព័ត៌មានហ្សែន ពូជសាសន៍ ឬជាតិសាសន៍ ភាសា អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ និងទិន្នន័យសព្វនាម។ ព័ត៌មានហ្សេនេទិចរបស់អ្នក រួមមានព័ត៌មានអំពីការធ្វើតេស្តហ្សេនេទិចរបស់អ្នក តេស្តហ្សេនេទិចរបស់សមាជិកគ្រួសារអ្នក និងសំណើឬការទទួលសេវាហ្សេនេទិចរបស់អ្នកឬសមាជិកគ្រួសារ។
- **ការប្រាស្រ័យទាក់ទងជាមួយគ្រួសារ និងអ្នកផ្សេងទៀតនៅពេលអ្នកមានវត្តមាន៖** ជួនកាលសមាជិកគ្រួសារម្នាក់ ឬបុគ្គលផ្សេងទៀតដែលចូលរួមក្នុងការថែទាំរបស់អ្នក នឹងមានវត្តមាននៅពេលយើងកំពុងពិភាក្សាអំពី PHI របស់អ្នកជាមួយអ្នក។ ប្រសិនបើអ្នកបដិសេធ សូមប្រាប់យើង ហើយយើងនឹងមិនពិភាក្សា PHI របស់អ្នកនោះទេ ឬយើងនឹងសុំឱ្យបុគ្គលនោះចាកចេញ។
- **ការប្រាស្រ័យទាក់ទងជាមួយគ្រួសារ និងអ្នកផ្សេងទៀតនៅពេលអ្នកមានវត្តមាន៖** មានពេលខ្លះវាមានភាពចាំបាច់ក្នុងការលាតត្រដាង PHI របស់អ្នកដល់សមាជិកគ្រួសារ ឬបុគ្គលផ្សេងទៀតដែលចូលរួមក្នុងការថែទាំរបស់អ្នក ដោយសារមានការសង្គ្រោះបន្ទាន់ដែលអ្នកមិនមានវត្តមាន ឬអ្នកខ្វះសមត្ថភាពធ្វើការសម្រេចចិត្តយល់ព្រមឬបដិសេធ។ ក្នុងករណីទាំងនោះ យើងនឹងប្រើប្រាស់ការវិនិច្ឆ័យតាមវិជ្ជាជីវៈរបស់យើង ដើម្បីសម្រេចថាតើវាជាឧត្តមប្រយោជន៍សម្រាប់អ្នកដែរឬទេនៅក្នុងការលាតត្រដាង PHI របស់អ្នក។ បើដូច្នោះ យើងនឹងកំណត់ការលាតត្រដាងចំពោះ PHI ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការចូលរួមរបស់បុគ្គលនៅក្នុងការថែទាំសុខភាពរបស់អ្នក។ ឧទាហរណ៍ យើងអាចអនុញ្ញាតឱ្យនរណាម្នាក់មកទទួលយកវេជ្ជបញ្ជាសម្រាប់អ្នក។

- **ការលាតត្រដាងក្នុងករណីមានការសង្គ្រោះពេលមានមហន្តរាយ៖** យើងអាចនឹងលាតត្រដាង ឈ្មោះ ទីក្រុងស្នាក់នៅ អាយុ ភេទ និងស្ថានភាពទូទៅរបស់អ្នកដល់អង្គការសង្គ្រោះគ្រោះ មហន្តរាយសាធារណៈ ឬឯកជន ដើម្បីជួយដល់កិច្ចខិតខំជួយសង្គ្រោះពេលមានគ្រោះ មហន្តរាយ ប្រសិនបើអ្នកមិនបដិសេធនៅពេលនោះទេ។
- **ការលាតត្រដាងជូនឪពុកម្តាយក្នុងនាមជាអ្នកតំណាងផ្ទាល់ខ្លួនរបស់អនីតិជន៖** ក្នុងករណី ភាគច្រើនយើងអាចបង្ហាញព័ត៌មាន PHI របស់កូនដែលជាអនីតិជនរបស់អ្នកជូនដល់អ្នក។ ប៉ុន្តែ នៅក្នុងស្ថានភាពមួយចំនួន ច្បាប់បានអនុញ្ញាត ឬថែមទាំងតម្រូវឱ្យយើងបដិសេធ សិទ្ធិចូលប្រើ PHI របស់កូនជាអនីតិជនរបស់អ្នកទៀតផង។ ឧទាហរណ៍អំពីពេលវេលាដែល យើងត្រូវបដិសេធសិទ្ធិចូលប្រើដោយផ្អែកលើប្រភេទសេវាថែទាំសុខភាព គឺនៅពេលដែល អនីតិជនមានអាយុ 12 ឆ្នាំឡើងទៅ ស្វែងរកការថែទាំសម្រាប់ជំងឺឆ្លងឬស្ថានភាពណាមួយ។ ស្ថានភាពផ្សេងទៀត នៅពេលដែលយើងត្រូវបដិសេធសិទ្ធិចូលប្រើចំពោះឪពុកម្តាយ គឺនៅពេលអនីតិជនមានសិទ្ធិជាមនុស្សពេញវ័យក្នុងការសម្រេចចិត្តលើការថែទាំសុខភាព ដោយខ្លួនឯងបាន។ ឧទាហរណ៍ អនីតិជនទាំងនេះរួមមាន អនីតិជនដែលធ្លាប់ ឬបាន រៀបការ ឬដែលទទួលបានការប្រកាសអត្តាធីនភាពពីតុលាការ។
- **បញ្ជីរាយឈ្មោះនៅមន្ទីរពេទ្យ៖** នៅពេលអ្នកជាអ្នកជំងឺនៅក្នុងមន្ទីរពេទ្យមួយក្នុង ចំណោមមន្ទីរពេទ្យរបស់យើង យើងអាចនឹងបង្កើតបញ្ជីមួយដែលរួមបញ្ចូលឈ្មោះ ទីតាំងបន្ទប់ និងស្ថានភាពទូទៅរបស់អ្នក។ ព័ត៌មាននេះអាចនឹងត្រូវបានផ្សព្វផ្សាយ ទៅដល់បុគ្គលដែលសួររកឈ្មោះអ្នក។ ម្យ៉ាងទៀត យើងអាចផ្តល់ជូនទំនាក់ទំនងផ្នែកសាសនា (ប្រសិនបើមាន) ជាមួយនឹងបុព្វជិតណាមួយ។ អ្នកអាចនឹងបដិសេធការប្រើប្រាស់ឬការ ផ្សព្វផ្សាយព័ត៌មាននេះផ្នែកខ្លះឬទាំងអស់បាន។ ប្រសិនបើអ្នកបដិសេធ យើងនឹងមិនលាត ត្រដាងព័ត៌មាននេះដល់អ្នកមកសួរសុខទុក្ខ ឬសាធារណជនផ្សេងទៀតទេ។
- **ការស្រាវជ្រាវ៖** Kaiser Permanente ចូលរួមក្នុងការស្រាវជ្រាវទូលំទូលាយសំខាន់ៗ។ ការសិក្សា ស្រាវជ្រាវរបស់យើងមួយចំនួន អាចមានពាក់ព័ន្ធនឹងនីតិវិធី ហើយខ្លះទៀតមានកំណត់ ត្រឹមការប្រមូលនិងវិភាគទិន្នន័យសុខភាព។ ការស្រាវជ្រាវគ្រប់ប្រភេទ អាចពាក់ព័ន្ធ នឹងការប្រើប្រាស់ ឬផ្សព្វផ្សាយ PHI របស់អ្នក។ PHI របស់អ្នក ជាទូទៅអាចត្រូវបានប្រើ ប្រាស់ឬផ្សព្វផ្សាយសម្រាប់ការស្រាវជ្រាវដោយគ្មានការអនុញ្ញាតរបស់អ្នក ប្រសិនបើ ក្រុមប្រឹក្សាត្រួតពិនិត្យតាមស្ថាប័ន (Institutional Review Board, IRB) ឯកភាពលើការ ប្រើប្រាស់ឬផ្សព្វផ្សាយនោះ។ តាមច្បាប់សហព័ន្ធ IRB គឺជាគណៈកម្មាធិការមួយ ដែលទទួលខុសត្រូវពិនិត្យ និងឯកភាពលើការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងមនុស្ស ដើម្បីការពារសុវត្ថិភាពអ្នកចូលរួម និងការសម្ងាត់របស់ PHI។
- **ការបរិច្ចាគសរីរាង្គ៖** យើងអាចប្រើប្រាស់ ឬលាតត្រដាង PHI ទៅអង្គការលទ្ធកម្មសរីរាង្គ ដើម្បីជួយដល់ការបរិច្ចាគសរីរាង្គ ភ្នែក ឬជាលិកាផ្សេងទៀត។

- **សកម្មភាពសុខភាពសាធារណៈ៖** សកម្មភាពសុខភាពសាធារណៈគ្របដណ្តប់លើមុខងារជាច្រើនដែលទីភ្នាក់ងាររដ្ឋាភិបាលបានអនុវត្តនិងអនុញ្ញាត ដើម្បីលើកកម្ពស់និងការពារសុខភាពសាធារណៈ ហើយអាចនឹងតម្រូវឱ្យយើងលាតត្រដាង PHI របស់អ្នក។
  - ឧទាហរណ៍ យើងអាចលាតត្រដាង PHI របស់អ្នកសម្រាប់ជាផ្នែកមួយនៃកាតព្វកិច្ចរបស់យើងក្នុងការរាយការណ៍ដល់អាជ្ញាធរសុខភាពសាធារណៈអំពីជំងឺ របួស ស្ថានភាព និងព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ដូចជាការសម្រាលកូនជាដើម។ ជួនកាល យើងអាចនឹងលាតត្រដាង PHI របស់អ្នកដល់នរណាម្នាក់ដែលអ្នកអាចប្រឈមនឹងជំងឺឆ្លង ឬដែលអាចមានហានិភ័យប្រឈមនឹងការឆ្លងឬការចម្លងជំងឺ។
  - រដ្ឋបាលចំណីអាហារ និងឱសថ (Food and Drug Administration, FDA) ទទួលខុសត្រូវតាមដាន និងត្រួតពិនិត្យផលិតផលវេជ្ជសាស្ត្រ ដូចជា ថ្នាំបេះដូង និងការផ្លាស់ប្តូរសន្លាក់ត្រគាកជាដើម ដើម្បីកំណត់រកបញ្ហា និងអលទ្ធភាពរបស់ផលិតផល ព្រមទាំងរបួសដែលផលិតផលទាំងនោះបង្កឡើង។ ប្រសិនបើអ្នកបានទទួលផលិតផលមួយក្នុងចំណោមផលិតផលទាំងនេះ យើងអាចនឹងប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នកដល់ FDA ឬបុគ្គលឬស្ថាប័នដែលទទួលបានការអនុញ្ញាតផ្សេងទៀត ដូចជាអ្នកផលិតផលិតផលនោះជាដើម។
  - យើងអាចនឹងប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នកទៅតាមការចាំបាច់ ដើម្បីអនុលោមតាមច្បាប់សហព័ន្ធ និងរដ្ឋដែលគ្រប់គ្រងលើសុវត្ថិភាពកន្លែងការងារ។
- **ការត្រួតពិនិត្យសុខភាព៖** ក្នុងនាមអ្នកផ្តល់សេវាថែទាំសុខភាព និងគម្រោងសុខភាព យើងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដែលធ្វើឡើងដោយទីភ្នាក់ងារសហព័ន្ធ និងរដ្ឋ។ ទីភ្នាក់ងារទាំងនេះអាចធ្វើសវនកម្មលើប្រតិបត្តិការ និងសកម្មភាពរបស់យើង ហើយក្នុងដំណើរការសវនកម្មនេះ ទីភ្នាក់ងារអាចនឹងពិនិត្យមើល PHI របស់អ្នក។
- **ការលាតត្រដាងដល់និយោជក ឬស្ថាប័ននិយោជិតរបស់អ្នក៖** ប្រសិនបើអ្នកបានចុះឈ្មោះក្នុង Kaiser Foundation Health Plan, Inc. តាមរយៈនិយោជក ឬស្ថាប័ននិយោជិតរបស់អ្នក យើងអាចនឹងចែករំលែក PHI ជាក់លាក់ដល់និយោជក ឬស្ថាប័ននិយោជិតទាំងនោះដោយគ្មានការអនុញ្ញាតរបស់អ្នក ប៉ុន្តែអាចធ្វើទៅបានតែក្នុងករណីដែលច្បាប់អនុញ្ញាតប៉ុណ្ណោះ។ ឧទាហរណ៍ យើងអាចនឹងផ្សព្វផ្សាយ PHI របស់អ្នកសម្រាប់ការទាមទារសំណងរបស់បុគ្គលិក ឬដើម្បីកំណត់ថាតើអ្នកបានចុះឈ្មោះនៅក្នុងគម្រោងឬអត់ ឬថាតើបុព្វលាភរ៉ាប់រងត្រូវបានទូទាត់ជំនួសអ្នកហើយឬនៅ។ សម្រាប់គោលបំណងផ្សេងទៀត ដូចជាសម្រាប់ការសាកសួរដោយស្ថាប័ននិយោជក ឬនិយោជិតរបស់អ្នកជំនួសឱ្យអ្នក យើងនឹងទទួលបានការអនុញ្ញាតរបស់អ្នក នៅពេលចាំបាច់នៅក្រោមច្បាប់ជាធរមាន។
- **សំណងរបស់បុគ្គលិក៖** យើងអាចប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នក ដើម្បីអនុលោមតាមច្បាប់ស្តីពីសំណងរបស់បុគ្គលិក។ ឧទាហរណ៍ យើងអាចទំនាក់ទំនងប្រាប់ព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកអំពីរបួស ឬជំងឺពាក់ព័ន្ធនឹងការងារទៅដល់រដ្ឋបាលផ្នែកទាមទារសំណងក្រុមហ៊ុនធានារ៉ាប់រង និងស្ថាប័នផ្សេងទៀតដែលទទួលខុសត្រូវធ្វើការវាយតម្លៃលើការទាមទាររបស់អ្នកសម្រាប់អត្ថប្រយោជន៍សំណងរបស់បុគ្គលិក។

- **សកម្មភាពយោធា និងសន្តិសុខជាតិ៖** ជួនកាល យើងអាចប្រើប្រាស់ ឬលាតត្រដាង PHI របស់កងកម្លាំងប្រដាប់អាវុធដល់អាជ្ញាធរយោធាជាធរមាន នៅពេលអាជ្ញាធរយោធានោះជឿជាក់ថាវាមានភាពចាំបាច់ក្នុងការអនុវត្តបេសកកម្មយោធាឱ្យបានសមស្រប។ យើងក៏អាចនឹងលាតត្រដាង PHI របស់អ្នកទៅដល់មន្ត្រីសហព័ន្ធដែលទទួលបានការអនុញ្ញាតទៅតាមការចាំបាច់សម្រាប់សកម្មភាពសន្តិសុខជាតិ និងសកម្មភាពស៊ើបការសម្ងាត់ ឬសម្រាប់ការការពារប្រធានាធិបតី និងមន្ត្រីរដ្ឋាភិបាល ព្រមទាំងអ្នកមុខការផ្សេងទៀត។
- **ការរំអេងគ្គាសថវិកា៖** យើងអាចនឹងប្រើប្រាស់ ឬលាតត្រដាងព័ត៌មានប្រជាសាស្ត្រ និង PHI មានដែនកំណត់ផ្សេងទៀត ដូចជា កាលបរិច្ឆេទ និងទីកន្លែងផ្តល់ការថែទាំសុខភាពជាដើម ដល់ស្ថាប័នជាក់លាក់ក្នុងគោលបំណងធ្វើការទាក់ទងទៅអ្នក ដើម្បីរៃអង្គាសថវិកាជូនស្ថាប័នរបស់យើង។ ប្រសិនបើយើងទាក់ទងទៅអ្នកសម្រាប់គោលបំណងរៃអង្គាសប្រាក់ យើងនឹងផ្តល់ឱ្យអ្នកនូវឱកាសច្បាស់លាស់ក្នុងការសម្រេចមិនទទួលការប្រាស្រ័យទាក់ទងប្រាប់អំពីការរៃអង្គាសប្រាក់នេះជាបន្តទៀត។
- **តម្រូវដោយច្បាប់៖** ក្នុងស្ថានភាពមួយចំនួន ច្បាប់សហព័ន្ធនិងរដ្ឋតម្រូវឱ្យយើងលាតត្រដាង PHI របស់អ្នកទៅដល់អ្នកដទៃ។ ឧទាហរណ៍ រដ្ឋលេខាធិការក្រសួងសុខាភិបាលនិងសេវាមនុស្សជាតិ អាចពិនិត្យមើលកិច្ចប្រឹងប្រែងអនុវត្តច្បាប់របស់អ្នក ដែលអាចនឹងរាប់បញ្ចូលទាំងការពិនិត្យមើល PHI របស់អ្នកផងដែរ។
- **បណ្តឹង និងវិវាទផ្នែកច្បាប់ផ្សេងទៀត៖** យើងអាចប្រើប្រាស់ និងលាតត្រដាង PHI ដើម្បីឆ្លើយតបទៅនឹងសេចក្តីបង្គាប់របស់តុលាការ ឬផ្នែករដ្ឋបាល ដីកាកោះ និងសំណើសុំព័ត៌មានរឿងក្តី។ យើងក៏អាចប្រើប្រាស់ និងលាតត្រដាង PHI ក្នុងកម្រិតដែលច្បាប់បានអនុញ្ញាតដោយគ្មានការអនុញ្ញាតរបស់អ្នក ឧទាហរណ៍ ដើម្បីតទល់បណ្តឹងផ្លូវច្បាប់ ឬមជ្ឈតកម្ម។
- **ការអនុវត្តច្បាប់៖** យើងអាចនឹងលាតត្រដាង PHI ដល់មន្ត្រីដែលទទួលបានការអនុញ្ញាតសម្រាប់គោលបំណងអនុវត្តច្បាប់ ឧទាហរណ៍ ដើម្បីឆ្លើយតបនឹងដីកាឆែកឆេរ រាយការណ៍អំពីបទឧក្រិដ្ឋនៅក្នុងទីតាំងរបស់យើង ឬជួយកំណត់អត្តសញ្ញាណឬស្វែងរកទីតាំងនរណាម្នាក់។
- **ការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព និងសុវត្ថិភាព៖** យើងអាចនឹងប្រើប្រាស់ និងលាតត្រដាង PHI របស់អ្នក ប្រសិនបើយើងជឿថាចាំបាច់ក្នុងការបញ្ចៀសការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពរបស់អ្នក ឬ របស់នរណាម្នាក់ផ្សេងទៀត។
- **ការរំលោភបំពាន ឬការធ្វេសប្រហែស៖** តាមច្បាប់ យើងអាចនឹងលាតត្រដាង PHI ដល់អាជ្ញាធរសមស្រប ដើម្បីរាយការណ៍អំពីកុមារដែលសង្ស័យថារងការរំលោភបំពាន ឬការធ្វេសប្រហែស ឬដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដែលសង្ស័យថារងការរំលោភបំពាន ការធ្វេសប្រហែស ឬការប្រើអំពើហិង្សាក្នុងគ្រួសារ។
- **អ្នកធ្វើកោសល្យវិច័យ និងអ្នកគ្រប់គ្រងពិធីបុណ្យសព៖** យើងអាចនឹងលាតត្រដាង PHI ដល់អ្នកធ្វើកោសល្យវិច័យ ឬអ្នកពិនិត្យវេជ្ជសាស្ត្រ ដើម្បីអាចកំណត់អត្តសញ្ញាសាកសព កំណត់ពីមូលហេតុនៃការស្លាប់ ឬសម្រាប់ភារកិច្ចផ្លូវការផ្សេងទៀត។ យើងក៏អាចផ្សព្វផ្សាយ PHI ទៅដល់អ្នកគ្រប់គ្រងពិធីបុណ្យសពផងដែរ។

- **អ្នកទោស៖** តាមច្បាប់សហព័ន្ធតម្រូវឱ្យយើងផ្តល់សេចក្តីជូនដំណឹងនេះដល់អ្នក តែអ្នកទោសមិនមានសិទ្ធិដូចគ្នានេះដើម្បីគ្រប់គ្រង PHI របស់ពួកគេដូចបុគ្គលផ្សេងទៀតឡើយ។ ប្រសិនបើអ្នកជាអ្នកទោសជាប់ក្នុងមណ្ឌលកែប្រែ ឬនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីអនុវត្តច្បាប់ណាម្នាក់ យើងអាចនឹងលាតត្រដាង PHI របស់អ្នកទៅកាន់មណ្ឌលកែប្រែឬមន្ត្រីអនុវត្តច្បាប់នោះ សម្រាប់គោលបំណងជាក់លាក់ណាមួយ រួមមានជាអាទិ៍ ដើម្បីការពារសុខភាពនិងសុវត្ថិភាពរបស់អ្នក ឬរបស់បុគ្គលផ្សេងទៀត។
- **ការលាក់អត្តសញ្ញាណ៖** យើងឬសម្ព័ន្ធក្រុមហ៊ុនអាជីវកម្មដែលយើងបានចុះកិច្ចសន្យាជាមួយ អាចប្រើប្រាស់ PHI ដើម្បីលាក់អត្តសញ្ញាណស្របតាមស្តង់ដា HIPAA ហើយអាចនឹងលាតត្រដាងទិន្នន័យដែលបានលាក់អត្តសញ្ញាណនោះដល់ភាគីទីបីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ KP។

## VI. រាល់ការប្រើប្រាស់ និងការលាតត្រដាងផ្សេងទៀតទាក់ទងនឹង PHI របស់អ្នក គឺតម្រូវឱ្យមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអ្នក។

លើកលែងតែការប្រើប្រាស់និងការលាតត្រដាងទាំងឡាយដែលបានរៀបរាប់ខាងលើ យើងនឹងមិនប្រើប្រាស់ ឬលាតត្រដាង PHI របស់អ្នកដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកឡើយ។ ឧទាហរណ៍មួយចំនួនដែលយើងអាចនឹងស្នើសុំការអនុញ្ញាតរបស់អ្នកសម្រាប់ការប្រើប្រាស់ និងការលាតត្រដាង PHI រួមមាន៖

- **ការធ្វើទីផ្សារ៖** យើងអាចនឹងសុំការអនុញ្ញាតពីអ្នក ដើម្បីផ្តល់ព័ត៌មានអំពីផលិតផលនិងសេវាកម្មដែលអ្នកអាចនឹងចាប់អារម្មណ៍ទិញ ឬប្រើប្រាស់។ សូមចំណាំថា ការប្រាស្រ័យទាក់ទងធ្វើទីផ្សារ មិនរួមបញ្ចូលការទាក់ទងរបស់យើងទៅអ្នកពាក់ព័ន្ធនឹងព័ត៌មានអំពីជម្រើសនៃការព្យាបាល ឱសថតាមវេជ្ជបញ្ជាដែលអ្នកកំពុងប្រើប្រាស់ ឬផលិតផលឬសេវាកម្មពាក់ព័ន្ធនឹងសុខភាពដែលយើងផ្តល់ជូន ឬដែលមានផ្តល់ជូនតែចំពោះអ្នកចុះឈ្មោះក្នុងផែនការសុខភាពរបស់យើងប៉ុណ្ណោះនោះទេ។ ការធ្វើទីផ្សារក៏មិនរួមបញ្ចូលការពិភាក្សាផ្ទាល់ទល់មុខគ្នាដែលអ្នកអាចនឹងធ្វើឡើងជាមួយអ្នកផ្តល់សេវារបស់អ្នកអំពីផលិតផលឬសេវាកម្មនោះទេ។
- **ការលក់ PHI៖** យើងអាចនឹងលក់ PHI របស់អ្នកក្នុងករណីដែលយើងទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នកមុនឱ្យធ្វើដូច្នោះតែប៉ុណ្ណោះ។
- **កំណត់សម្គាល់អំពីការព្យាបាលចិត្តសាស្ត្រ៖** ក្នុងករណីកម្រ យើងអាចនឹងស្នើសុំការអនុញ្ញាតរបស់អ្នកដើម្បីប្រើប្រាស់ និងលាតត្រដាង "កំណត់សម្គាល់អំពីការព្យាបាលចិត្តសាស្ត្រ"។ ច្បាប់ឯកជនភាពសហព័ន្ធកំណត់និយមន័យ "កំណត់សម្គាល់អំពីការព្យាបាលចិត្តសាស្ត្រ" យ៉ាងជាក់លាក់ថា ជាកំណត់សម្គាល់ដែលធ្វើឡើងដោយអ្នកជំនាញវិជ្ជាជីវៈសុខភាពផ្លូវចិត្ត ដែលកត់ត្រាការសន្ទនានៅអំឡុងពេលពិគ្រោះលក្ខណៈឯកជនឬជាក្រុម ដែលត្រូវបានរក្សាទុកដាច់ដោយឡែកពីកំណត់ត្រាវេជ្ជសាស្ត្រផ្សេងទៀតរបស់អ្នក។ ជាទូទៅ យើងមិនរក្សាទុកកំណត់សម្គាល់អំពីការព្យាបាលចិត្តសាស្ត្រ ដូចបានកំណត់និយមន័យដោយច្បាប់ឯកជនភាពសហព័ន្ធនោះទេ។

- **កំណត់សម្គាល់ការប្រឹក្សាយោបល់អំពីវិបត្តិនៃការប្រើប្រាស់សារធាតុញៀន (SUD)៖** ក្នុងករណីកម្រ យើងអាចស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកដើម្បីប្រើប្រាស់ និងលាតត្រដាង "កំណត់សម្គាល់ការប្រឹក្សាយោបល់អំពី SUD"។ ច្បាប់ឯកជនភាពសហព័ន្ធកំណត់ "កំណត់សម្គាល់ការប្រឹក្សាយោបល់អំពី SUD" យ៉ាងជាក់លាក់បំផុតដែលមានន័យថាជាកំណត់សម្គាល់ដែលត្រូវបានកត់ត្រាទុក (តាមមធ្យោបាយណាមួយ) ដោយអ្នកផ្តល់កម្មវិធី SUD ដែលជាអ្នកជំនាញផ្នែក SUD ឬសុខភាពផ្លូវចិត្តដែលចងក្រងជាឯកសារ ឬវិភាគខ្លឹមសារនៃសន្ទនាក្នុងអំឡុងពេលវគ្គប្រឹក្សាយោបល់អំពី SUD ឯកជន ឬវគ្គប្រឹក្សាយោបល់អំពី SUD ជាក្រុម ឬរួមគ្នា ឬជាគ្រួសារ ហើយដែលត្រូវបានរក្សាទុកដាច់ដោយឡែកពីកំណត់ត្រាវេជ្ជសាស្ត្រ និង SUD របស់អ្នកជំងឺផ្សេងទៀត។ ជាទូទៅ យើងមិនរក្សាទុក កំណត់សម្គាល់ការប្រឹក្សាយោបល់អំពី SUD ដូចដែលបានកំណត់ដោយច្បាប់ឯកជនភាពសហព័ន្ធនោះទេ។

**កំណត់ត្រានៃវិបត្តិនៃការប្រើប្រាស់សារធាតុញៀន (SUD)៖**

- កំណត់ត្រា SUD របស់អ្នក ឬសក្ខីកម្មដែលបញ្ជាក់ពីខ្លឹមសារនៃកំណត់ត្រា SUD របស់អ្នក នឹងមិនត្រូវបានប្រើប្រាស់ ឬលាតត្រដាងនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី រដ្ឋបាល ព្រហ្មទណ្ឌ ឬនីតិប្បញ្ញត្តិណាមួយប្រឆាំងនឹងអ្នកឡើយ លុះត្រាតែយើងមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់ពីអ្នក ឬមានដីកាពីតុលាការ។
- កំណត់ត្រា SUD របស់អ្នកនឹងត្រូវបានប្រើប្រាស់ ឬលាតត្រដាងតែលើមូលដ្ឋាននៃដីកាតុលាការ បន្ទាប់ពីមានការជូនដំណឹង និងការផ្តល់ឱកាសឱ្យមានការផ្តល់មតិដល់អ្នក ឬអ្នកកាន់កាប់កំណត់ត្រានោះប៉ុណ្ណោះ។
- ដីកាតុលាការដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬការលាតត្រដាងត្រូវតែភ្ជាប់មកជាមួយនូវដីកាកោះ ឬដីកាបង្គាប់តាមផ្លូវច្បាប់ស្រដៀងគ្នាផ្សេងទៀតដែលបង្ខំឱ្យលាតត្រដាងមុនពេលកំណត់ត្រា SUD របស់អ្នកត្រូវបានប្រើប្រាស់ ឬលាតត្រដាង។

នៅពេលតម្រូវឱ្យមានការអនុញ្ញាតរបស់អ្នក ហើយអ្នកអនុញ្ញាតឱ្យយើងប្រើប្រាស់និងលាតត្រដាង PHI សម្រាប់គោលបំណងមួយចំនួន អ្នកអាចបដិសេធការអនុញ្ញាតនោះដោយជូនដំណឹងទៅយើងជាលាយលក្ខណ៍អក្សរបានគ្រប់ពេល។ សូមចំណាំថា ការបដិសេធនោះនឹងមិនអនុវត្តចំពោះការប្រើប្រាស់ ឬការលាតត្រដាងដែលទទួលបានការអនុញ្ញាតលើ PHI របស់អ្នក ដែលបានកើតឡើងមុនពេលយើងទទួលបានការបដិសេធរបស់អ្នកនោះទេ។ ម្យ៉ាងទៀត ប្រសិនបើអ្នកបានផ្តល់ឱ្យយើងនូវការអនុញ្ញាតដើម្បីរក្សាសុវត្ថិភាពគោលការណ៍ធានារ៉ាប់រង រួមមានការរ៉ាប់រងការថែទាំសុខភាពពីយើងជាដើម នោះអ្នកមិនអាចបដិសេធការអនុញ្ញាតនោះបានទេ លុះត្រាតែក្រុមហ៊ុនធានារ៉ាប់រងលែងអាចប្រឆាំងជំទាស់លើគោលការណ៍ដែលផ្តល់ជូនអ្នក ឬការទាមទារនៅក្រោមគោលការណ៍នោះតទៅទៀតបាន។

## VII. របៀបទាក់ទងមកយើងខ្ញុំអំពីការជូនដំណឹងនេះ ឬដើម្បីប្តឹងតវ៉ាអំពីការអនុវត្តឯកជនភាពរបស់យើង

ប្រសិនបើអ្នកមានសំណួរអំពីសេចក្តីជូនដំណឹងនេះ ឬចង់ធ្វើការប្តឹងតវ៉ាអំពីការអនុវត្តឯកជនភាពរបស់យើង សូមសរសេរសំបុត្រមកកាន់ Director of Privacy & Security Compliance, Kaiser Permanente Ethics & Compliance Office, 1 Kaiser Plaza, Oakland, CA 94612, 19th Floor។ ឬប្រាប់ពួកយើងតាមរយៈការហៅទូរសព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាបម្រើសមាជិកតាមលេខ 1-800-464-4000 (TTY 711)។ អ្នកក៏អាចជូនដំណឹងដល់លេខាធិការនៃក្រសួងសុខាភិបាល និងសេវាមនុស្សជាតិផងដែរ។

យើងនឹងមិនចាត់វិធានការសងសឹកប្រឆាំងនឹងអ្នកឡើយ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងអំពីការអនុវត្តឯកជនភាពរបស់យើង។

## VIII. ការផ្លាស់ប្តូរចំពោះសេចក្តីជូនដំណឹងនេះ

យើងអាចនឹងកែប្រែសេចក្តីជូនដំណឹងនេះ និងការអនុវត្តឯកជនភាពរបស់យើងបានគ្រប់ពេល ដរាបណាការកែប្រែនេះស្របទៅតាមច្បាប់របស់រដ្ឋនិងសហព័ន្ធ។ រាល់ការជូនដំណឹងដែលបានកែប្រែនឹងត្រូវអនុវត្តទាំងចំពោះ PHI ដែលយើងមានរួចហើយអំពីអ្នកនៅពេលមានការកែប្រែនោះ និងទាំងចំពោះ PHI ណាមួយដែលបានបង្កើតនិងទទួលបានក្រោយការកែប្រែនោះចូលជាធរមាន។ ប្រសិនបើយើងធ្វើការកែប្រែសំខាន់លើការអនុវត្តឯកជនភាពរបស់យើង នោះយើងនឹងផ្លាស់ប្តូរសេចក្តីជូនដំណឹងនេះភ្លាមៗ ហើយដាក់សេចក្តីជូនដំណឹងថ្មីនៅលើគេហទំព័របណ្តាញរបស់យើងតាមរយៈ www.kp.org/privacy។ លើកលែងតែការកែប្រែនានាដែលច្បាប់បានតម្រូវ យើងនឹងមិនធ្វើការកែប្រែណាមួយចំពោះការអនុវត្តឯកជនភាពរបស់យើង មុនពេលយើងកែប្រែសេចក្តីជូនដំណឹងនេះឡើយ។

## IX. កាលបរិច្ឆេទមានប្រសិទ្ធភាពនៃសេចក្តីជូនដំណឹងនេះ

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2026។

សេចក្តីជូនដំណឹងបន្ថែមស្តីពីការអនុវត្តឯកជនភាពខាងក្រោមសម្រាប់សមាជិកនៃ Kaiser Foundation Health Plan Medi-Cal Plan គឺអនុវត្តចំពោះតែសមាជិក Medi-Cal ដែលបានចុះឈ្មោះជាមួយ Kaiser Foundation Health Plan តាមរយៈអង្គភាពណាមួយក្នុងចំណោមអង្គភាពដូចខាងក្រោមប៉ុណ្ណោះ៖ Geographic Managed Care Sacramento ឬ Geographic Managed Care San Diego ឬ Prepaid Health Plan។ សេចក្តីជូនដំណឹងបន្ថែមនេះមានរួមបញ្ចូលនៅក្នុងសៀវភៅណែនាំរបស់សមាជិក Medi-Cal។

សេចក្តីជូនដំណឹងបន្ថែមអំពីការអនុវត្តឯកជនភាពសម្រាប់សមាជិក របស់
Kaiser Foundation Health Plan Medi-Cal Plan*

សេចក្តីជូនដំណឹងនេះពណ៌នាអំពីរបៀបដែលព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកអាចត្រូវបានប្រើប្រាស់ និងលាតត្រដាង ព្រមទាំងរបៀបដែលអ្នកអាចចូលប្រើប្រាស់ព័ត៌មាននេះ។

ក្នុងនាមជាសមាជិកថ្មី អ្នកគួរទទួលបាន (ឬនឹងទទួលបានឆាប់ៗ) ច្បាប់ចម្លងនៃសេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាពរបស់ Kaiser Permanente Northern California Regional or Southern California Regional HIPAA (“សេចក្តីជូនដំណឹងថ្នាក់តំបន់”) ភ្ជាប់ជាមួយបណ្ណសម្គាល់ Kaiser Permanente ថ្មីរបស់អ្នក។ សេចក្តីជូនដំណឹងថ្នាក់តំបន់នេះប្រាប់អ្នកអំពីសិទ្ធិរបស់អ្នក និងភារកិច្ចផ្លូវច្បាប់របស់យើងពាក់ព័ន្ធនឹងព័ត៌មានសុខភាពរបស់អ្នក។ សេចក្តីជូនដំណឹងថ្នាក់តំបន់នេះក៏ពណ៌នា និងផ្តល់ឧទាហរណ៍អំពីពេលវេលាដែលច្បាប់អនុញ្ញាតឱ្យយើងប្រើប្រាស់ និងលាតត្រដាងព័ត៌មានសុខភាពដែលត្រូវបានការពារមួយចំនួនដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកផងដែរ៖ ឧទាហរណ៍ សម្រាប់ការព្យាបាល ឬសម្រាប់កិច្ចដំណើរការថែទាំសុខភាព ដូចជា ការកែលម្អគុណភាពជាដើម។

សេចក្តីជូនដំណឹងបន្ថែមនេះគឺសម្រាប់សមាជិកគម្រោង Kaiser Permanente Medi-Cal។ សេចក្តីជូនដំណឹងបន្ថែមនេះប្រាប់អ្នកអំពីភាពខុសគ្នានៅក្នុងច្បាប់រដ្ឋ ដែលក្នុងស្ថានភាពមួយចំនួនតម្រូវឱ្យយើងទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកក្នុងនាមជាសមាជិក Medi-Cal ដើម្បីលាតត្រដាងព័ត៌មានសុខភាព តែមិនតម្រូវឱ្យយើងទទួលបានការអនុញ្ញាតជាលាយលក្ខន៍អក្សរពីនរណាម្នាក់ដែលមិនមែនជាសមាជិក Medi-Cal ឡើយ។

តាមច្បាប់រដ្ឋដែលអនុវត្តចំពោះអ្នកទទួលផល MEDI-CAL នោះ KAISER PERMANENTE ត្រូវការការអនុញ្ញាតរបស់អ្នក ដើម្បីប្រើប្រាស់ ឬលាតត្រដាងព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកក្នុងស្ថានភាពខាងក្រោម៖

- ដើម្បីផ្តល់ព័ត៌មានវេជ្ជសាស្ត្រដល់អង្គការលទ្ធកម្មសរីរាង្គ ប្រសិនបើព័ត៌មានវេជ្ជសាស្ត្រនោះមិនពាក់ព័ន្ធនឹងការព្យាបាលរបស់អ្នកទេ នៅពេលអ្នកជាបេក្ខជន ឬអ្នកទទួលការវះកាត់ប្តូរសរីរាង្គ
- ដើម្បីអនុលោមតាមច្បាប់ស្តីពីសុវត្ថិភាពកន្លែងការងារ ឬច្បាប់ស្តីពីសំណងរបស់បុគ្គលិក លើកលែងតែការលាតត្រដាងសម្រាប់ការព្យាបាល ឬដល់មន្ត្រីក្នុងតំបន់ ឬរដ្ឋ
- ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនផ្សេងទៀតធ្វើទីផ្សារផលិតផល ឬសេវាកម្មរបស់ខ្លួនដល់អ្នក
- ដើម្បីរៃអង្គាសថវិកាសម្រាប់ស្ថាប័នរបស់យើង
- ដើម្បីឆ្លើយតបនឹងដីកាកោះ ឬសេចក្តីបង្គាប់របស់តុលាការ ឬបទបញ្ជារបស់ទីភ្នាក់ងាររដ្ឋាភិបាល លើកលែងតែសំណើទាំងនោះពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មវិធី Medi-Cal ឬទទួលបានការអនុញ្ញាតពីច្បាប់
- ដើម្បីរាយការណ៍បញ្ហាអំពីផលិតផលវេជ្ជសាស្ត្រជាក់លាក់ដល់ FDA ឬបុគ្គលឬស្ថាប័នផ្សេងទៀត ដូចជា អ្នកផលិតផលិតផលនោះជាដើម។

លើកលែងតែក្នុងករណីទាំងនេះ Kaiser Permanente អាចនឹងប្រើប្រាស់ ឬលាតត្រដាងព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកដូចបានពណ៌នានៅក្នុងសេចក្តីជូនដំណឹងថ្នាក់តំបន់នេះ។

លើកលែងតែមានការកែប្រែដោយសេចក្តីជូនដំណឹងបន្ថែមនេះដែលអនុវត្តចំពោះអ្នកក្នុងនាមជាសមាជិក Medi-Cal សេចក្តីជូនដំណឹងថ្នាក់តំបន់នេះនៅតែយកមកអនុវត្ត។ ឧទាហរណ៍ ដូចបានកំណត់ចំណាំនៅក្នុងសេចក្តីជូនដំណឹងថ្នាក់តំបន់ អ្នកមានសិទ្ធិស្នើសុំចូលប្រើប្រាស់កំណត់ត្រារបស់អ្នក។ ឧទាហរណ៍មួយទៀត គឺផ្នែកពាក់ព័ន្ធនឹងការកែប្រែសេចក្តីជូនដំណឹងថ្នាក់តំបន់ក៏អនុវត្តចំពោះសេចក្តីជូនដំណឹងបន្ថែមផងដែរ។ ។

សេចក្តីជូនដំណឹងថ្នាក់តំបន់នេះក៏ប្រាប់អ្នកអំពីរបៀបទាក់ទងមកយើងផងដែរ ប្រសិនបើអ្នកមានសំណួរអំពីសេចក្តីជូនដំណឹងថ្នាក់តំបន់។ ប្រសិនបើអ្នកមានសំណួរណាមួយអំពីសេចក្តីជូនដំណឹងបន្ថែមនេះ ឬអ្នកចង់ធ្វើការប្តឹងតវ៉ាអំពីការអនុវត្តឯកជនភាពរបស់យើង សូមហៅទូរសព្ទមកមជ្ឈមណ្ឌលផ្តល់ព័ត៌មានផ្នែកសេវាបម្រើសមាជិកតាមលេខ 1-800-464-4000។
អ្នកក៏អាចជូនដំណឹងដល់មន្ត្រីផ្នែកឯកជនភាពនៃក្រសួងសេវាសុខាភិបាល California តាមទូរសព្ទ ឬជាលាយលក្ខណ៍អក្សរដោយប្រើព័ត៌មានទំនាក់ទំនងនៅខាងចុងសេចក្តីជូនដំណឹងបន្ថែមនេះបានផងដែរ។

យើងទទួលខុសត្រូវការពារព័ត៌មានសុខភាពរបស់សមាជិក និងអ្នកជំងឺទាំងអស់យ៉ាងហ្មត់ចត់ ហើយនឹងបន្តចាត់វិធានការសមស្របដើម្បីការពារព័ត៌មានទាំងនោះ។ សូមអរគុណចំពោះការផ្តល់សេវាថែទាំសុខភាពរបស់អ្នកមកលើ Kaiser Permanente។

Si necesita ayuda en su idioma, llame a nuestro Centro de Llamadas para Servicios a los Miembros al 1-800-788-0616.

ព័ត៌មានទំនាក់ទំនងសម្រាប់មន្ត្រីផ្នែកឯកជនភាពនៃក្រសួងសេវាសុខាភិបាល California៖

Privacy Officer

California Department of Health Services

P.O. Box 942732

Sacramento, CA 94234-7320

(916) 255-5259 ឬ 1-877-735-2929 (TTY) * Geographic Managed Care Sacramento, Geographic Managed Care San Diego ឬ Prepaid Health Plan។